រាជធានីភ្នំពេញ ; ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៩៤

សេចក្ដីសំរេចលេខ ១១៧ សសរ.

ស្ដីពីការ បង្កើតគណៈកម្មការត្រួតពិនិត្យការបាត់បង់ សំភារៈនៅនាយកដ្ឋានសំភារៈនៃក្រសួងសាធារណៈការ និង ដឹកជញ្ជូន

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញ រដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ វរ័ន្ម ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញ ច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងសាធារណៈការ និង ដឹកជញ្ជូន ។

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីចុះត្រួតពិនិត្យការបាត់បង់សំភារៈ នៅនាយកដ្ឋានសំភារៈនៃក្រសួងសាធារណៈការនិងដឹកជញ្ជូន ដែលមានសមាសភាពដូចខាងក្រោម :

១-	ឯកឧត្ដម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬតំណាង	ប្រធាន
២-	តំណាងរាជរដ្ឋាភិបាល (លេខាធិការដ្ឋានអធិការកិច្ច)	អនុប្រធាន
៣-	តំណាងក្រសួងសាធារណៈការ និង ដឹកជញ្ជូន	សមាជិក
៤-	តំណាងក្រសួងពាណិជ្ជកម្ម	សមាជិក
៥-	តំណាងធនាគារជាតិកម្ពុជា	សមាជិក

ប្រការ ២ : គណៈកម្មការនេះ មានភារកិច្ច :

- ត្រួតពិនិត្យសំភារៈ នៅនាយកដ្ឋានសំភារៈ នៃ ក្រសួងសាធារណៈការ និង ដឹកជញ្ជូន ។
- ធ្វើរបាយការណ៍ ស្តីពីសំភារៈដែលបាត់បង់មូលហេតុ នៃការបាត់បង់ និង សំភារៈដែលនៅសេសសល់ និងលើកវិធានការការពារ ថែរក្សាសំភារៈ ដែលនៅសេសសល់ជូនរាជរដ្ឋាភិបាលពិនិត្យ និង សំរេច ។

ប្រការ ៣ : សមាជិក គណៈកម្មការ ត្រូវអញ្ជើញចូលរួមប្រជុំ និង អនុវត្តការងារ តាមការណែនាំរបស់ប្រធាន ។ គណៈកម្មការ មានសិទ្ធិប្រើប្រាស់ត្រាក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីដំណើរការងាររបស់ខ្លួន ។

ប្រការ ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការ គណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អគ្គទេសាភិបាលធនាគារជាតិកម្ពុជា រដ្ឋមន្ត្រីក្រសួង សាធារណការ និង ដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បណ្តាក្រសួង រដ្ឋលេខាធិការដ្ឋាន ដែលមានការពាក់ព័ន្ធ និង ឯកឧត្តមអស់លោក ដែលមានចែងក្នុងប្រការ ១ ត្រូវអនុវត្តតាមសេចក្តី សំរេចនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	ហ៊ុន សែន

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៩៤

សេចក្ដីសំរេចលេខ ១១៨ សសរ.

ស្ដីពីការផ្ទេរសិទ្ធិ

រាជរដ្ឋាភិបាល

-បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្ដម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញ ច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-តាមសំណើរបស់ឯកឧត្ដម គាត ឈន់ ទេសរដ្ឋមន្ត្រី ទទួលបន្ទុក គ.ជ.នា

សំរេច

ប្រការ ១ : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្ដម សុខ អាន រដ្ឋមន្ត្រីទទួលបន្ទុក ទីស្ដីការគណៈរដ្ឋមន្ត្រី ជំនួសឯកឧត្ដម គាត ឈន់ ទេសរដ្ឋមន្ត្រីទទួលបន្ទុក គ.ជ.នា ដែលត្រូវអញ្ជើញទៅបំពេញ បេសកកម្មនៅបរទេស ចាប់ពីថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៤ រហូតដល់ថ្ងៃ ឯកឧត្ដម គាត ឈន់ វិលត្រឡប់មកវិញ ។

ប្រការ ២ : សហរដ្ឋមន្ត្រី ទទួលបន្ទុកទីស្ដីការ គណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និង ឯកឧត្ដមដែលមានឈ្មោះ ក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសំរេចនេះតាមភារកិច្ចរៀង ៗ ខ្លួនចាប់ពីថ្ងៃឡាយព្រះហស្ដលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ដលេខា និងត្រា	ហត្ថលេខា និងត្រា
នរោត្ដម រណឫទ្ធិ	ហ៊ុន សែន

រាជធានីភ្នំពេញ , ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៩៤

សេចក្តីសំរេចលេខ ១១៩ សសរ.

ស្តីពីការផ្ទេរសិទ្ធិ

រាជរដ្ឋាភិបាល

-បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ័ន្ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញ ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-តាមសំណើររបស់ឯកឧត្តម ម៉ុម ជីមហ៊ុយ រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និង កីឡា

សំរេច

ប្រការ ១ : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម អ៊ីម ឈុនលឹម រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជំនួស ឯកឧត្តម ម៉ុម ជីមហ៊ុយ រដ្ឋលេខាធិការក្រសួងអប់រំយុវជន និង កីឡា ដែលត្រូវអញ្ជើញទៅបំពេញទស្សនកិច្ច នៅបរទេស ចាប់ពីថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៤ រហូតដល់ថ្ងៃ ដែលឯកឧត្តម រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា វិលត្រឡប់មកវិញ ។

ប្រការ ២ : សហរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការ គណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ

គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និង ឯកឧត្តមដែលមានឈ្មោះ ក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះតាមភារៈកិច្ចរៀងៗ ខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និងត្រា ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ ហ៊ុន សែន

* * *

II ការងារបណ្តាក្រសួង

ធីស្តីការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

ប្រកាស

ប្រកាសលេខ ១៣៦ បធ .ប្រក ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ១៩៩៤

ស្តីពីការតែងតាំង បជិគ្គាហកៈ មន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍

រដ្ឋលេខាធិការ ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញ ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ និងប្រកាសអោយប្រើនៅ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤